**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តប៉ៃលិន**

-សំណុំរឿងព្រហ្មទណ្ឌ
លេខ ០១ អ.ក
ចុះថ្ងៃទី០១-មករា-២០២៣
-សំណុំរឿងជំនុំជម្រះលេខ **២៧**
ចុះថ្ងៃទី០៦-មេសា-២០២៣
-សាលក្រមព្រហ្មទណ្ឌ
លេខ **៦៣ "ឃ"**
ចុះថ្ងៃទី១៨-កក្កដា-២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តប៉ៃលិន

បានបើកសវនាការជាសាធារណៈនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
- លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តប៉ៃលិន

## ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តប៉ៃលិន

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] **ចាវ** ភេទប្រុស កើតថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០១ ជនជាតិខ្មែរ មុខរបរជាងសាក់ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] សាវ៉ាន់ "ស" ម្តាយឈ្មោះ [redacted] សុខជា "រ" កម្រិតវប្បធម៌ថ្នាក់ទី០៧ ជានីតិជន ទោសពីមុន "គ្មាន"។ **(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ០២ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ )**

ជាប់ចោទពីបទ **"លួចមានស្ថានទម្ងន់ទោស"** ប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

- មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖**

- ឈ្មោះ [redacted] **ថាត** ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិរោងចក្រ សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។
- ឈ្មោះ [redacted] **សុភ័ណ** ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាលិច សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។



Scanned with CamScanner

- ឈ្មោះ [redacted]តុលា ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិបរយ៉ាខា សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

- ឈ្មោះ [redacted] **សុផា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិអូរពីត សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

- ឈ្មោះ [redacted] **ផេង** ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិអូរច្រាកណ្តាល សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

-ឈ្មោះ [redacted] **យ៉ារិន** ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិអូរតាពុកក្រោម សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន ។

- បានឃើញ ដីកាដំណោះស្រាយលេខ **៣៩៦/២៣** ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន ។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ **៦២ ព្រ.១/២៣** ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តប៉ៃលិន ។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ២យប់ មានឈ្មោះ [redacted] **ចាវ** ភេទប្រុស អាយុ២១ឆ្នាំ បានធ្វើសកម្មភាពចូលលួចកាត់សោរទ្វាររបស់វិទ្យាល័យក្រុងទេពនិមិត្ត ស្ថិតនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន បានលួចយកកុំព្យូទ័រឡេបថបចំនួន ០២គ្រឿង, អាយផេតចំនួន ០១គ្រឿង, ម៉ាស៊ីនព្រីនចំនួន ០១គ្រឿង, ស្ពាយចំនួន ០២គ្រឿង និងខ្សែរភ្លើងចំនួន ០១ដុំ ។ ពេលលួចបានហើយឈ្មោះ [redacted] ចាវ បានយករបស់ទាំងអស់នោះទៅទុកនៅក្នុងព្រៃ និងបានយកកុំព្យូទ័រឡេបថបចំនួន ០២គ្រឿង ដាក់លើកង់ជិះចេញមកសំដៅទៅផ្ទះរបស់សង្សាខ្លួននៅភូមិបរយ៉ាខា ។ ពេលកំពុងជិះកង់តាមផ្លូវស្រាប់តែបានជួបជាមួយកងកម្លាំងល្បាតចល័តដែលកំពុងចុះល្បាត ក្រោយមកសមត្ថកិច្ចបានឃាត់ខ្លួន និងនាំជនជាប់ចោទឈ្មោះ [redacted] **ចាវ** ទៅសួរចម្លើយនៅអធិការដ្ឋាននគរបាលក្រុងប៉ៃលិន ។ បន្ទាប់មកសមត្ថកិច្ចបានរៀបចំសំណុំរឿង និងបញ្ជូនសំណុំរឿង ព្រមទាំងជនជាប់ចោទទៅកាន់ស្ថាប័នអយ្យការអមសាលាដំបូង ដើម្បីចាត់ការបន្តតាមច្បាប់ នៅដំណាក់កាលអយ្យការជនជាប់ចោទឈ្មោះ [redacted] **ចាវ** បានសារភាពថាខ្លួនពិតជាបានធ្វើសកម្មភាពលួចនៅក្នុងក្រុងប៉ៃលិន បានចំនួន ០៦ដងហើយ ។

## នាពេលសវនាការ

### ការកត់សម្គាល់ខ្លីៗ បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាដេញដោល:

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាវ** បានឆ្លើយថា ៖ ខ្លួនពិតបានធ្វើសកម្មភាពលួចកាត់សោរទ្វារបន្ទប់សាលាវិទ្យាល័យហ៊ុនសែនក្រុងទេពនិមិត្ត ដែលស្ថិតនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដោយលួចយកបានកុំព្យូទ័រឡេបថប់ចំនួន ០២គ្រឿង,អាយផេត ១គ្រឿង,ម៉ាស៊ីនព្រីន ២គ្រឿង,ស្ពាយ ២គ្រឿង និងខ្សែរភ្លើង ១ដុំ ពិតមែន ។ ពេលដែលលួចរបស់ទាំងនោះបានហើយ ខ្លួនបានយករបស់ទាំងនោះទៅលាក់ទុកក្នុងព្រៃ បន្ទាប់មកខ្លួនបានយកកុំព្យូទ័រលេបថបចំនួន ១គ្រឿង ជិះកង់ចេញពីព្រៃម្តុំសាលាវិទ្យាល័យទេពនិមិត្ត ពេលដែលកំពុងជិះកង់តាមផ្លូវនោះ ស្រាប់តែបានជួបនឹងកម្លាំងសមត្ថកិច្ច ទើបសមត្ថកិច្ចមានការសង្ស័យ



Scanned with CamScanner

បានធ្វើការឃាត់ខ្លួនដើម្បីសួរចម្លើយតែម្តង ។ ខ្លួនសូមសារភាពថា នៅក្នុងក្រុងប៉ៃលិននេះខ្លួនពិតជាធ្លាប់បានធ្វើសកម្មភាពលួចបានចំនួន ០៦លើកមកហើយ ។

- តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ថាត បានឆ្លើយថា ៖ កាលពីយប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ នៅម៉ោងប្រហែល ២យប់ ខ្លួនបានបាត់កង់ជិះហាត់ប្រាណចំនួន ០១គ្រឿង ពណ៌ក្រហមលាយពណ៌ខ្មៅ មានតម្លៃ ៣៨០(បីរយប៉ែតសិប)ដុល្លារ ។ ក្រោយពេលបានដឹងថាបាត់កង់ ខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់បរយ៉ាខាតែម្តង ។

- តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] សុភ័ណ្ឌ បានឆ្លើយថា ៖ កាលពីយប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ខ្លួនបានបាត់របស់របរមួយចំនួនដូចជា ស្វានបុកចំនួន ១, ប៉ុស្តិ៍ផ្សារចំនួន ១, ម៉ូទ័រកាត់ការ៉ូចំនួន ១ និងខ្សែភ្លើងចំនួន ១ដុំ នៅយប់នោះខ្លួនមិនបានដឹងថាបាត់តាំងពីស្មោលណានោះទេ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ទើបខ្លួនបានដឹងបានបាត់របស់ទាំងនោះ ។ សម្ភារៈដែលបានបាត់បើសរុបជាតម្លៃប្រហែលជា ៨០០,០០០(ប្រាំបីសែន)រៀល បន្ទាប់ពីខ្លួនបានដឹងថាបាត់របស់ហើយខ្លួនបានដាក់ពាក្យបណ្តឹងទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់បរយ៉ាខាតែម្តង ។

- តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] យ៉ារិន បានឆ្លើយថា ៖ កាលពីយប់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ មានចោរចូលកាត់សោរនៅទីចាត់ការវិទ្យាល័យហ៊ុនសែនក្រុងទេពនិមិត្ត លួចយកសម្ភារៈមួយចំនួនដូចជា កុំព្យូទ័រម៉ាកASUS ចំនួន ០២គ្រឿង(ពណ៌ទឹកប្រាក់ និងពណ៌ប្រផេះ), ម៉ាស៊ីនព្រីនចំនួន ០២គ្រឿង ម៉ាកEPSON និងម៉ាកCANON ពណ៌ខ្មៅ , ក្បាលអិលស៊ីឌីចំនួន ០២គ្រឿង, ថេបប្លេកចំនួន ០១គ្រឿង និងខ្សែភ្លើងចំនួន ០១ដុំ ប្រហែលជា ៨០(ប៉ែតសិប)ម៉ែត្រ ។ ខ្លួនបានប្តឹងទៅសមត្ថកិច្ចរដ្ឋបាលសង្កាត់ទួលល្វា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: បន្ទាប់ពីឆ្លងកាត់កិច្ចពិភាក្សាដេញដោលនាពេលសវនាការ ការស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ និងការស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចាវ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ។ ដូច្នេះតំណាងអយ្យការប្តឹងសូមរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងសូមឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឆ្លងកាត់តាមការស្តាប់ចម្លើយសារភាពគ្រប់ដំណាក់កាលរបស់កូនក្តីខ្ញុំ និងការពិភាក្សាដេញដោលនាសវនាការ ឃើញថា នៅគ្រប់ដំណាក់កាលទាំងអស់ចាប់តាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌មក កូនក្តីរបស់ខ្ញុំបាទបានឆ្លើយសារភាពថាខ្លួនពិតជាធ្លាប់បានធ្វើសកម្មភាពលួចអស់ចំនួន ០៦ដងហើយ កូនក្តីរបស់ខ្ញុំបានបង្ហាញពីស្មារតីភ្ញាក់រលឹកដឹងកំហុសដែរ ។ ដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ វ៉ាន់ ចាវ ខ្ញុំបាទស្នើសុំតុលាការឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង ។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] ចាវ ៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសផង ។

## តុលាការ

- ក្រោយពីបាន ស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ។
- ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។



Scanned with CamScanner

- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនរងគ្រោះ ។
- ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង ។
- ក្រោយពីបាន ពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

**១.យល់ឃើញថា:** កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ពិតជាមានអង្គហេតុលួចដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ចាវ** ពិតប្រាកដមែន ។

**២.យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] **ចាវ** ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ប៉ៃលិន ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងសម្រេចបញ្ជូនទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តប៉ៃលិន ដើម្បីជំនុំជម្រះពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

**៣.យល់ឃើញថា:** អង្គហេតុនៃបទល្មើសបានកើតឡើងប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដែលជាទីកន្លែងស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់តុលាការព្រហ្មទណ្ឌ នៃសាលាដំបូងខេត្ត ប៉ៃលិន ។ ដូច្នេះ តុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តប៉ៃលិនមានសមត្ថកិច្ចដែនដីធ្វើការជំនុំជម្រះ ទៅលើរឿងក្តីនេះបាន ស្របតាមមាត្រា **២៩០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា **២០** នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ។

**៤.យល់ឃើញថា:** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាវ** បានឆ្លើយនាពេលសវនាការថា៖ ខ្លួនពិតបានធ្វើសកម្មភាពលួចកាត់សោរទ្វារបន្ទប់សាលាវិទ្យាល័យហ៊ុនសែនក្រុងទេពនិមិត្ត ដែលស្ថិតនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដោយលួចយកបានកុំព្យូទ័រឡេបថប់ចំនួន ០២គ្រឿង,អាយផេត ១គ្រឿង,ម៉ាស៊ីនព្រីន ២គ្រឿង,ស្គាយ ២គ្រឿង និងខ្សែរភ្លើង ១ដុំ ពិតមែន ។ ពេលដែលលួចរបស់ទាំងនោះបានហើយ ខ្លួនបានយករបស់ទាំងនោះទៅលាក់ទុកក្នុងព្រៃ បន្ទាប់មកខ្លួនបានយកកុំព្យូទ័រលេបថបចំនួន ១គ្រឿង ជិះកង់ចេញពីព្រៃម្តុំសាលាវិទ្យាល័យទេពនិមិត្ត ពេលដែលកំពុងជិះកង់តាមផ្លូវនោះ ស្រាប់តែបានជួបនឹងកម្លាំងសមត្ថកិច្ច ទើបសមត្ថកិច្ចមានការសង្ស័យបានធ្វើការឃាត់ខ្លួនដើម្បីសួរចម្លើយតែម្តង ។ ខ្លួនសូមសារភាពថា នៅក្នុងក្រុងប៉ៃលិននេះខ្លួនពិតជាធ្លាប់បានធ្វើសកម្មភាពលួចបានចំនួន ០៦លើកមកហើយ ។

**៥.យល់ឃើញថា:** តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីឆ្លងកាត់កិច្ចពិភាក្សាដេញដោលនាពេលសវនាការ ការស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ និងការស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ចាវ** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ។ ដូច្នេះតំណាងអយ្យការប្តឹងសុំរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងសូមឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

**៦.យល់ឃើញថា:** តាមរបាយការណ៍ព្រឹត្តហេតុលេខ ០៤/២០២២ រ.ប.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ចុះរបស់អធិការដ្ឋាននគរបាលក្រុងប៉ៃលិន និងរបាយការណ៍សំយោគលេខ ២២/២០២២ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានបញ្ជាក់ថា ពិតជាមានករណី **លួច** ដែលបង្កឡើងដោយឈ្មោះ [redacted] **ចាវ** ពិតប្រាកដមែន ។



Scanned with CamScanner

**៧.យល់ឃើញថា:** តាមរយៈចម្លើយសារភាពរបស់ជនជាប់ចោទ, អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានាក្នុងសំណុំរឿង មានធាតុផ្សំនៃបទល្មើស និងភស្តុតាងនៃពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាវ** ដែលបានធ្វើសកម្មភាពកាត់សោរទ្វារចូលលួចរបស់របរនៅសាលាវិទ្យាល័យហ៊ុនសែនក្រុងទេពនិម្មិត ដែលអំពើរបស់ជនជាប់ចោទខាងលើ កំណត់បានជាបទល្មើស **"លួចមានស្ថានទម្ងន់ទោស"** ប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចប្រកាសពីពិរុទ្ធភាព និងប្រកាសផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា **៣៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៨.យល់ឃើញថា:** ជនជាប់ចោទ គឺជានីតិជន និងជាជនមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌដោយមិនមានមូលហេតុណាមួយ ដែលត្រូវទទួលបានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**៩.យល់ឃើញថា:** អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាវ** ដែលបានប្រព្រឹត្តអំពើនេះ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងប្រឆាំងនឹងច្បាប់រដ្ឋ ។ ដូច្នេះ គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ផ្អែកតាមកាលៈទេសៈនៃបទល្មើស បុគ្គលិក លក្ខណៈនៃជនជាប់ចោទតាម មាត្រា **៩៦** នៃក្រមព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ចាវ** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

- ដាក់ពន្ធនាគារកំណត់រយៈពេល **០៤(បួន)ឆ្នាំ** ។

ពីបទ **"លួចមានស្ថានទម្ងន់ទោស"** ប្រព្រឹត្តនៅភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចាវ** ។

**បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។**

**ក្រុមប្រឹក្សាជំនុំជម្រះ**
**ហត្ថលេខា និងត្រា:**
[redacted]

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមសាលក្រមដើម**
ថ្ងៃអង្គារ ១កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ប៉ៃលិន, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]



Scanned with CamScanner